ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

# សាលដីកា
## តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ១៨០
ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៩
សាលដីកា
លេខ ៦៦ VII
ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០ ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម៖

១.លោកស្រី [redacted] ប្រធាន (ចៅក្រមរបាយការណ៍)

២.លោក [redacted] ចៅក្រម

៣.លោក [redacted] ចៅក្រម

៤.លោកស្រី [redacted] ចៅក្រម

៥.លោក [redacted] ចៅក្រម

### ក្រឡាបញ្ជីសវនាការ

-លោក [redacted]

### តំណាងមហាអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញា

### ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ២១៦ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៩ របស់ អគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍ ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៥៤ ក្រV " វ " ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ដែលមានជនជាប់ចោទ ៖

១.ឈ្មោះ [redacted] កុកងី ហៅ ពេជ្រ សុភា ភេទប្រុស អាយុ ២០ឆ្នាំ ជនជាតិខ្មែរ កើតនៅភូមិ [redacted] ខេត្តបាត់ដំបង មានទីលំនៅបច្ចុប្បន្ន នៅភូមិ [redacted] ខេត្ត



Scanned with CamScanner

បាត់ដំបង ឪពុកឈ្មោះ [redacted] (ស) ម្ដាយឈ្មោះ [redacted] (ស) ទោសពីមុនគ្មាន ឃុំខ្លួនលេខ ២៨៥ ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៨ ។

-មានលោកស្រី [redacted] សុវ៉ន ជាមេធាវីការពារសិទ្ធិ

-ជាប់ចោទពីបទ: រួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ ប្រព្រឹត្តនៅចំណុចភូមិអូរខ្ចាយ ឃុំវត្តតាមិម ស្រុកសង្កែ ខេត្តបាត់ដំបង កាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង ឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៤២ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

-ជនរងគ្រោះឈ្មោះ [redacted] ឈូឈូ អាយុ ១២ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅ [redacted] ខេត្តបាត់ដំបង ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] រតនៈ ភេទប្រុស អាយុ ៤៨ឆ្នាំ មានទីលំនៅ [redacted] ខេត្តបាត់ដំបង ។

**១.អំពីអង្គហេតុ:**

តាមដីកាសន្និដ្ឋានស្ថាពរលេខ: ១៣៩០ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៨ របស់ព្រះរាជអាជ្ញាបានកំណត់ថា កាលពីថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ កម្លាំងសមត្ថកិច្ចរបស់អធិការដ្ឋាននគរបាលស្រុកសង្កែបានចុះបង្ក្រាបករណីរួមភេទជាមួយអនីតិជន ដោយឃាត់ខ្លួនបានជនសង្ស័យម្នាក់ឈ្មោះ [redacted] កុកងី ។ ក្រោយសាកសួរជនសង្ស័យឆ្លើយថា ខ្លួនបានទៅយកជនរងគ្រោះឈ្មោះ [redacted] ឈូឈូ ភេទស្រី កើតថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៦ មកពីផ្ទះមកដេកនៅផ្ទះសំណាក់នៅម្ដុំផ្សារលើ ហើយបានរួមភេទជាមួយគ្នាបានចំនួន ០២ដងក្នុងយប់នោះ និងនៅជាមួយគ្នារហូតដល់ថ្ងៃដែលសមត្ថកិច្ចឃាត់ខ្លួន ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ២៦ "ខ" ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តបាត់ដំបង ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖

១-ផ្ដន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] កុកងី ហៅ ពេជ្រ សុភា ភេទប្រុស អាយុ ២០ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០៤ (បួន) ឆ្នាំ ។

ពីបទ ៖ រួមភេទជាមួយអនីតិជនអាយុក្រោម ១៥ឆ្នាំ ប្រព្រឹត្តនៅចំណុចភូមិអូរខ្ចាយ ឃុំវត្តតាមិម ស្រុកសង្កែ ខេត្តបាត់ដំបង កាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង ឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា៤២ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

២.សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ ។

-បានឃើញ បណ្ដឹងឧទ្ធរណ៍លេខ ០៧ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩ របស់លោក [redacted] សុផុន ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តបាត់ដំបង ប្ដឹងមិនសុខចិត្តទៅនឹងសាលក្រមព្រហ្មទណ្ឌលេខ ២៦ "ខ" ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តបាត់ដំបង គ្រប់ចំណុចសេចក្ដីសម្រេចទាំងមូល ។

Scanned with CamScanner

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៥៤ ក្រV " រ " ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១.ទទួលពាក្យបណ្តឹងឧទ្ធរណ៍របស់លោក [redacted] តំណាងអយ្យការអមសាលាដំបូងខេត្តបាត់ដំបង ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២៦ "ខ" ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តបាត់ដំបង ទុកជាបានការដដែល ។

៣.បន្តឃុំខ្លួនពិរុទ្ធជនតាមនីតិវិធីច្បាប់ ។

សាលដីកានេះជំនុំជម្រះ ជាសាធារណៈនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ចំពោះមុខពិរុទ្ធជន មេធាវី ការពារសិទ្ធិឲ្យពិរុទ្ធជន និងប្រកាសជាសាធារណៈ នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ។

បើកសិទ្ធិប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

-បានឃើញ បណ្តឹងសាទុក្ខលេខ ២១៦ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៩ របស់អគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍ ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ៥៤ ក្រV " រ " ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

**២.នាពេលសវនាការ**

-ចៅក្រមបានអានរបាយការណ៍ ។

-តំណាងមហាអយ្យការអមតុលាការកំពូល ធ្វើសេចក្តីសន្និដ្ឋានថា បណ្តឹងសាទុក្ខលេខ ២១៦ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៩ របស់លោក [redacted] អគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះ មកជំនុំជម្រះបានតាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ មាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ជនជាប់ចោទ បានទទួលស្គាល់នៅអំពើរបស់ខ្លួនហើយ ក៏បានស៊ីសង្វាក់ទៅនឹងចម្លើយកុមាររងគ្រោះផងដែរ ដែលពួកគេទាំងពីរពិតជាបានរួមភេទ តែជនរងគ្រោះជាកុមារី អាយុ១២ឆ្នាំ តែប៉ុណ្ណោះ ។ ហេតុដូច្នេះ អង្គហេតុនេះ គឺមានធាតុផ្សំ ពីបទរួមភេទជាមួយអនីតិជន ក្រោម១៥ឆ្នាំ ប្រាកដមែន បើទោះបីជាអ្នកទាំងពីរបានអះអាងថា ការរួមភេទបានធ្វើឡើងដោយការព្រមព្រៀងក៏ដោយ ។ ជនជាប់ចោទ មានវ័យក្មេង និងរួមភេទដោយសារអ្នកទាំងពីរ បានស្រលាញ់គ្នាខ្លះផង គួរតែត្រូវបានពិចារណាលើស្ថានសម្រាលទោស ។ តំណាងមហាអយ្យការយល់ឃើញថា សាលដីរបស់សាលាឧទ្ធរណ៍ ដែលបានសម្រេចមកនេះត្រឹមត្រូវហើយ ដូច្នេះសូមក្រុមប្រឹក្សាមេត្តាពិនិត្យ និងសម្រេចតាមច្បាប់ ។

-ក្រឡាបញ្ជីបានអានសារណាតបរបស់ជនជាប់ចោទឈ្មោះ [redacted] កុកងី ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩ ។

-លោកស្រី [redacted] សុវ៉ន ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] កុកងី បានធ្វើសេចក្តីសន្និដ្ឋានថា ករណីអង្គហេតុខាងលើនេះ គឺកើតចេញពីរឿងព្រមព្រៀង ប៉ុន្តែបញ្ហាចោទនោះ ជនរងគ្រោះគឺជាអនីតិ

Scanned with CamScanner

ជន ។ កូនក្តីខ្លួន ក៏មិនមានចេតនាទុច្ចរិតក្នុងការរួមភេទនោះដែរ ព្រោះកូនក្តីខ្លួនបានសួរទៅជនរងគ្រោះ ហើយជនរងគ្រោះបានអះអាង ដោយផ្សំនឹងរូបរាងកាយខាងក្រៅ គឺធ្វើកូនក្តីខ្លួនយល់ថាជនរងគ្រោះជានីតិជន ។ ចំណុចផ្សេងទៀត គឺតុលាការសាលាដំបូងបានសម្រេចដាក់ទោសកូនក្តីខ្លួនរយៈពេល ០៤ (បួន) ឆ្នាំ តាមបញ្ញត្តិមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ ឃើញថាមានលក្ខណៈត្រឹមត្រូវហើយ ព្រោះកូនក្តីខ្លួនបានសួរទៅជនរងគ្រោះអំពីនីតិភាពក្នុងការរួមភេទ ទើបកូនក្តីខ្លួនធ្វើការរួមភេទ ប៉ុន្តែជាក់ស្តែងដោយសារសំបុត្រកំណើតរបស់ជនរងគ្រោះ ជាភស្តុតាងដាក់បន្ទុក ទើបធ្វើឱ្យកូនក្តីខ្លួនមិនអាចគេចផុតពីបទល្មើសនេះបាន ។ បើពិនិត្យទៅលើ បញ្ញត្តិមាត្រា ៤២ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ គឺបានកម្រិតទណ្ឌចាប់ពី ០៥(ប្រាំ)ឆ្នាំ ទៅដល់ ១០ (ដប់)ឆ្នាំ ប៉ុន្តែបើមើលទៅលើភាពជាក់ស្តែង គឺកូនក្តីខ្លួនមិនមានចេតនាទុច្ចរិតណាមួយនោះទេ ទើបតុលាការសម្រេចដាក់ទណ្ឌកម្មក្រោមអប្បបរមា តាមបញ្ញត្តិមាត្រា ៤២ នេះ ។ សំណូមពរ ដល់ក្រុមប្រឹក្សាជំនុំជម្រះ តម្កល់សាលក្រមរបស់សាលាដំបូង ក៏ដូចជាសាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ
- ក្រោយពីបាន ពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២១៦ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៩ របស់អគ្គព្រះរាជអាជ្ញារងអមសាលាឧទ្ធរណ៍ ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះ មកជំនុំជម្រះបាន តាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤២០ នៃនីតិវិធីព្រហ្មទណ្ឌ។

២-យល់ឃើញថា ការដែលអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ជំទាស់នឹងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ ដែលបានផ្តន្ទាទោសជនជាប់ចោទដាក់ពន្ធនាគារ ៤ឆ្នាំ ដោយអគ្គព្រះរាជអាជ្ញាលើកឡើងថា ទោសដែលត្រូវបានផ្តន្ទាទោសបានប្រកាស ៤ឆ្នាំ ស្ថិតនៅក្រោមអប្បបរមា នៃទោសកំណត់ក្នុងមាត្រា ៤០ នៃច្បាប់ស្តីពីការជួញដូរមនុស្ស ដូច្នេះទើបប្តឹងសាទុក្ខជាប្រយោជន៍ច្បាប់នោះ អគ្គព្រះរាជអាជ្ញាមិនបានធ្វើសារណាជាលាយល័ក្ខអក្សរ តាមបញ្ញាតិនៃមាត្រា ៤២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ ។ ដូច្នេះ បណ្តឹងសាទុក្ខនេះ មិនមានការបង្ហាញអំពីមធ្យោបាយខាងច្បាប់ ដើម្បីឱ្យតុលាការកំពូលពិចារណាទេ ។

៣-យល់ឃើញថា ជនជាប់ចោទ និងជនរងគ្រោះស្ម័គ្រចិត្តរួមភេទទៅវិញទៅមកដោយគ្មានការបង្ខិតបង្ខំទេ អ្នកអន្តរាគមន៍គឺឪពុករបស់ជនរងគ្រោះ ទើបមានការប្តឹងមកសមត្ថកិច្ច ។ ដូច្នេះការដែលសាលាឧទ្ធរណ៍ជ្រើសរើសទណ្ឌកម្មកំណត់ ៤ឆ្នាំ នោះគឺជាការចូនល្មមហើយ ទោះបីជាទណ្ឌកម្មនេះស្ថិតក្រោមអប្បបរមានៃទោស ក៏តុលាការអាចប្រកាសបាន បើតុលាការបានសំអាងហេតុគ្រប់គ្រាន់ហើយ ។

Scanned with CamScanner

៤-យល់ឃើញថា បណ្តឹងសាទុក្ខរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មិនមានមូលហេតុសមស្របដូចការកំណត់នៃមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ ។

៥-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៥៤ ក្រV "វ" ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ ២០១៩ របស់សាលាឧទ្ធរណ៍ ត្រឹមត្រូវ នឹងគតិច្បាប់ ។

**ហេតុដូច្នេះ**

**សម្រេច**

១.**បដិសេធ** បណ្តឹងសាទុក្ខលេខ ២១៦ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៩ របស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។

២.**តម្កល់** សាលដីកាព្រហ្មទណ្ឌលេខ ៥៤ ក្រV "វ" ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ ២០១៩ របស់សាលាឧទ្ធរណ៍ ទុកជាបានការទាំងមូល ។

សាលដីកានេះ ជំនុំជម្រះ ជាសាធារណៈ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០ និងប្រកាសនា សវនាការជាសាធារណៈថ្ងៃទី១៨ ខែមីនា ឆ្នាំ ២០២០។

Scanned with CamScanner